ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣ អនក្រ.បក

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
លេខ: [illegible]
ថ្ងៃទី [illegible] ម៉ោង [illegible]
បញ្ជូន [illegible]

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ សន/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សំរេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ៖**

អនុក្រឹត្យនេះកំណត់ តួនាទី មុខងារ សមត្ថកិច្ច និងរៀបចំរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ជំពូក ២

## តួនាទី មុខងារ សមត្ថកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២ ៖**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីដ៏សំខាន់ក្នុងការប្រមូលពត៌មាន និងចូលរួមប្រតិបត្តិការប្រឆាំងនឹងការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀនខុសច្បាប់ និងសំរបសំរួលរាល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀនរបស់អង្គភាពប្រតិបត្តិដទៃទៀត ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពនៃការបង្ក្រាបគ្រឿងញៀនខុសច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។ នៅក្នុងតួនាទីនេះ អគ្គលេខាធិការដ្ឋានមានមុខងារសំខាន់ៗ ដូចតទៅ ÷

១. រៀបចំជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរាជរដ្ឋាភិបាល នូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព បង្ក្រាបការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀនខុសច្បាប់ និងការប្រើបំពានគ្រឿងញៀន ដោយសំរបសំរួលឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. តាមដានការអនុវត្តន៍គោលនយោបាយ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៣. ជំរុញ និងសំរបសំរួលវិធានការត្រួតពិនិត្យគ្រឿងញៀនដែលរៀបចំឡើងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ។

៤. រៀបចំជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរាជរដ្ឋាភិបាលនូវគោលនយោបាយជាតិ ស្តីពីវិធានការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

៥. ធ្វើទំនាក់ទំនងជាមួយនិងរដ្ឋាភិបាលបរទេស និងអង្គការអន្តរជាតិនានា ក្នុងការត្រួតពិនិត្យគ្រឿងញៀន។

**មាត្រា ៣ :-**

នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទី និងមុខងាររបស់ខ្លួនខាងលើនេះ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវមានសមត្ថកិច្ចដូចតទៅ :

១. រៀបចំ និងចូលរួមក្នុងកិច្ចពិភាក្សារបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

២. អនុវត្តតាមស្មារតីនៃអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២, អនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និងសារធាតុដែលធ្វើឱ្យប៉ះពាល់សរសៃប្រសាទ ឆ្នាំ១៩៨៨ ។

៣. ជំរុញ និងសំរបសំរួលការប្រមូលពត៌មាន និងស្ថិតិដែលកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិ ដើម្បីឱ្យស្ថាប័នមានសមត្ថកិច្ច បញ្ជូន និងផ្តល់ពត៌មានទាំងនោះ ទៅអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដែលមានសមត្ថកិច្ចឱ្យបានទាន់ពេលកំណត់ ។

៤. រៀបចំ និងតាក់តែងនូវសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានទាំងឡាយ ក្នុងវិស័យអប់រំ បង្ការទប់ស្កាត់ និងបង្ក្រាបការដាំដុះ ការផលិត ការធ្វើជំនួញគ្រឿងញៀន ការទាញផលចំណេញពីគ្រឿងញៀន និងការសំអាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត។

៥. រៀបចំលិខិតបទដ្ឋានសុវត្ថិភាពនៃការវេចខ្ចប់ ការប្រគល់ទទួល ការរក្សាទុក និងការកំទេចចោលគ្រឿងញៀនដែលចាប់បាន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៦. ត្រួតពិនិត្យ និងបង្ក្រាបការដាំដុះ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬការសំចតគ្រឿងញៀន និងសារធាតុផ្សំថ្មីៗទៀតសំរាប់ផលិតគ្រឿងញៀន ឱសថដែលមានសារធាតុ

ញៀន និងថ្នាំញៀនស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដោយសហការជាមួយក្រសួង-ស្ថាប័ន និង អង្គការពាក់ព័ន្ធដទៃទៀត។

៧. តាមដាន និងអនុវត្តច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបទប្បញ្ញត្តិផ្សេងៗដែលទាក់ទងទៅនឹងបទល្មើសគ្រឿងញៀន ព្រមទាំងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃនីតិវិធីតុលាការ ។

៨. ដាក់ឱ្យដំណើរការនូវប្រព័ន្ធមួយសំរាប់ពិនិត្យ តាមដាន និងវិភាគការប្រើប្រាស់គ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៩. រៀបចំ និងអនុវត្តកម្មវិធីអប់រំ ផ្សព្វផ្សាយ និងបង្ការកុំឱ្យមានការប្រើបំពានគ្រឿងញៀនដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

១០. សំរបសំរួលសកម្មភាពរបស់រដ្ឋាភិបាល ប្រឆាំងនឹងការសំអាតប្រាក់ដែលទាក់ទងនឹងជំនួញគ្រឿងញៀនខុសច្បាប់ ។

១១. សំរបសំរួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាសំរាប់អ្នកញៀនគ្រឿងញៀន ។

១២. រៀបចំ និងអនុវត្តកម្មវិធី ព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ដើម្បីជួយឱ្យពួកគេមានឱកាសបានមករស់នៅក្នុងភាពធម្មតាឡើងវិញ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធ ។

១៣. រៀបចំមជ្ឈមណ្ឌលពតិមានគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

១៤. រៀបចំកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៤ :-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានរចនាសម្ព័ន្ធជានាយកដ្ឋាន និងអង្គភាពដែលមានថ្នាក់ស្មើនាយកដ្ឋានរួមមាន ÷

១- នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ

២- នាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាល

៣- នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ

៤- នាយកដ្ឋានអនុវត្តច្បាប់

៥- នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា

៦- នាយកដ្ឋាន ស្រាវជ្រាវ និងត្រួតពិនិត្យ

៧- មន្ទីរពិសោធន៍គ្រឿងញៀន

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៥ :-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ដែលមានអគ្គលេខាធិការរងជាជំនួយការ ។

**មាត្រា ៦ :-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិធ្វើត្រាប្រើប្រាស់តាមសេចក្តីត្រូវការ ។

អគ្គលេខាធិការមានសិទ្ធិធ្វើសេចក្តីសំរេចតែងតាំង ឬ ផ្លាស់ប្តូរតំណែងនូវមន្ត្រីបុគ្គលិករបស់អគ្គ-លេខាធិការដ្ឋាន ចាប់ពីថ្នាក់ប្រធានផ្នែកចុះ។ ចំពោះការតែងតាំង ឬ ផ្លាស់ប្តូរតំណែងមន្ត្រីរាជការចាប់ពីអនុប្រធានការិយាល័យឡើងទៅ អគ្គលេខាធិការមានភារកិច្ចស្នើសុំប្រធានអាជ្ញាធរជាតិ ដើម្បីសំរេច ។

ក្នុងករណីចាំបាច់ អគ្គលេខាធិការ អាចមានសិទ្ធិជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាអោយមកបំពេញការងារនៅអគ្គលេខាធិការដ្ឋានតាមលក្ខខណ្ឌកំណត់ ។

## ជំពូក ៣
## នាយកដ្ឋាន

**មាត្រា ៧ :- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ÷**

១. សំរបសំរួលរាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ។

២. គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន ។

៣. សរុប និងធ្វើរបាយការណ៍សភាពការណ៍គ្រឿងញៀន និងសកម្មភាពការងាររបស់អាជ្ញាធរជាតិ អគ្គលេខាធិការដ្ឋាន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ។

៤. គ្រប់គ្រងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ។

៥. លើក និងអនុវត្តគំរោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន ។

៦. ប្រមូលផ្តុំចំណូល និងចំណាយរបស់អគ្គលេខាធិការដ្ឋាន ។

៧. តាមដាន និងរំលឹកការអនុវត្តន៍ថវិកា និងគ្រប់គ្រងគណនីរបស់អគ្គលេខាធិការដ្ឋាន ។

៨. គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភារៈ ធ្វើបញ្ជីសារពើភ័ណ្ឌរបស់អគ្គលេខាធិការដ្ឋាន ។

៩. រៀបចំ និងបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន ។

១០. ទទួល និងបែងចែកបរិក្ខារ ជូនដល់អង្គភាពទៅតាមកម្មវិធីចំណាយរបស់អគ្គលេខាធិការដ្ឋាន ។

១១. រៀបចំនិងទទួលរាល់កិច្ចប្រជុំរបស់អគ្គលេខាធិការដ្ឋាននិងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

១២. ធានាប្រសិទ្ធភាពផ្នែករដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន ។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជា ជំនួយការ ។

**មាត្រា ៨ :- នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល មានភារកិច្ចដូចតទៅ ÷**

១. រៀបចំយុទ្ធសាស្ត្រ និងលើកផែនការ គោលនយោបាយក្នុងការបង្ក្រាបការដាំដុះ ការផលិត ការជួញដូរ ការនាំចេញ និងនាំចូល ការដឹកជញ្ជូន នូវគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. រៀបចំគំរោងសកម្មភាព ដើម្បីអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារ ឆ្នាំ ១៩៧២, អនុសញ្ញា ស្តីពីសារធាតុ

ដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និងសារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ ១៩៨៨ ។

៣. ពិនិត្យតាមដានការអនុវត្តន៍គោលនយោបាយ និងសេចក្តីសំរេចរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៤. រៀបចំផែនការថ្នាក់ជាតិ និងគ្រប់គ្រងគំរោងដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៥. រៀបចំ និងអនុវត្តនយោបាយ ស្តីពីការបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

៦. សហការជាមួយអង្គការជាតិ និងអន្តរជាតិដើម្បីយល់ដឹងអំពីគោលការណ៍របស់តំបន់ អនុតំបន់ និងអន្តរជាតិ ស្តីពីគ្រឿងញៀន ។

នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាន ជាជំនួយការ ។

**មាត្រា ៩ :- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ ÷**

១. ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលបរទេស និងអង្គការអនុតំបន់ ឬអន្តរជាតិនានា ។

២. បញ្ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវអាស័យដ្ឋានរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិ។

៣. សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការបញ្ជូនពត៌មាន និងស្ថិតិដែលកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិ ទៅអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ។

៤. ចូលរួមក្នុងសកម្មភាពប្រចាំអនុតំបន់នានា ឬអន្តរជាតិ ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

**មាត្រា ១០ :- នាយកដ្ឋានអនុវត្តច្បាប់ មានភារកិច្ចដូចតទៅ ÷**

១. ស្រាវជ្រាវ និងប្រមូលពត៌មានពាក់ពន្ធ័នឹងគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. ត្រួតពិនិត្យ និងបង្រ្កាបការដាំដុះ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬសំចតគ្រឿងញៀន ឱសថដែលមានសារធាតុញៀន និងថ្នាំញៀនស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដោយសហការជាមួយ ក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៣. តាមដាន និងអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសាលក្រមតុលាការដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

៤. រៀបចំលិខិតបទដ្ឋានសុវត្ថិភាពស្តីពីការវេចខ្ចប់ ការប្រគល់ទទួល ការរក្សាទុក និងការកំទេចចោលគ្រឿងញៀនដែលចាប់បាន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៥ រៀបចំ និងគ្រប់គ្រងមជ្ឈមណ្ឌលពត៌មានគ្រឿងញៀន ។

៦. សំរបសំរួល និងចូលរួមក្នុងការបង្កើត និងអនុវត្តនូវកម្មវិធីប្រឆាំងនឹងការសំអាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ។

នាយកដ្ឋានអនុវត្តច្បាប់ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

**មាត្រា ១១ :- នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា មានភារកិច្ចដូចតទៅ ÷**

១. រៀបចំ និងអនុវត្តកម្មវិធីអប់រំបង្ការ ទប់ស្កាត់ និងកាត់បន្ថយការប្រើបំពានគ្រឿងញៀននៅក្នុងប្រទេស ដោយសំរបសំរួល និងសហការឱ្យបានល្អជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២.	រៀបចំ សំរបសំរួល និងអនុវត្តកម្មវិធីសំរាប់ទទួលព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងជួយឱ្យពួកគេក្លាយទៅជាពលរដ្ឋល្អរបស់សង្គមដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៣.	ជំរុញ និងលើកកំពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀនដល់សហគមន៍នានា ដើម្បីរួមចំណែកក្នុងការជួយទប់ស្កាត់ការប្រើបំពានគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៤.	ជំរុញឱ្យមានការរៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារ នីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៥.	ជំរុញការអនុវត្តន៍កម្មវិធីសមាហរណកម្មអ្នកញៀនគ្រឿងញៀនទៅក្នុងសង្គមជាតិវិញ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៦.	អនុវត្តកិច្ចសហប្រតិបត្តិការ និងអន្តរាគមន៍គាំទ្រដល់សកម្មភាពអនុវត្តច្បាប់របស់ភ្នាក់ងារអនុវត្តច្បាប់ដទៃទៀត ស្របតាមនីតិវិធី ។

៧.	តាក់តែងសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងបទបញ្ញត្តិ ក្នុងវិស័យបង្ការនិងបង្រ្កាបការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៨.	តាមដានការវិវត្តន៍នីតិក្រមរបស់រដ្ឋ និងលើកសំណើធ្វើវិសោធនកម្មច្បាប់ កែសំរួលព្រះរាជក្រឹត្យ អនុក្រឹត្យ និងបទបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនឹងគ្រឿងញៀន ក្នុងន័យធ្វើអោយដំណើរការនៃការត្រួតពិនិត្យគ្រឿងញៀនកាន់តែមានប្រសិទ្ធភាព ។

នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

**មាត្រា ១២ :- នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យ មានភារកិច្ចដូចតទៅ ៖**

១.	ស្រាវជ្រាវ ក្តាប់សភាពការណ៍ ប្រមូលពតិមានទូទៅដែលពាក់ព័ន្ធនឹងសារធាតុគីមី និងសារធាតុទាំងឡាយដែលប្រើប្រាស់សំរាប់ផ្សំគ្រឿងញៀន ព្រមទាំងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃ

ប្រសាទ និងឱសថដែលមានសារធាតុញៀន សំដៅលើកវិធានការគ្រប់គ្រង ត្រួតពិនិត្យ និងទប់ស្កាត់ឱ្យមានប្រសិទ្ធភាព ។

២. សហការ និងចូលរួមក្នុងកិច្ចប្រតិបត្តិការជាមួយក្រសួង និងអង្គភាពពាក់ព័ន្ធដទៃទៀត ក្នុងការតាមដាន និងត្រួតពិនិត្យ សារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុគីមីសំរាប់ផលិតគ្រឿងញៀន និងឱសថដែលមានសារធាតុញៀន និងថ្នាំញៀនស្របច្បាប់ កំណត់ដោយក្រសួងសុខាភិបាល ។

៣. សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការត្រួតពិនិត្យ តាមដាន និងទប់ស្កាត់ការនាំចេញ នាំចូល ការចរាចរ ការប្រើប្រាស់ ការផលិត ការស្តុកទុកនូវសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ។

៤. សហការក្នុងការទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំ ពីជំនួញស្របច្បាប់ ទៅបំរើគោលដៅផលិតគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គការដទៃទៀត ។

នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

## ជំពូក ៤
## មន្ទីរពិសោធន៍គ្រឿងញៀន

**មាត្រា ១៣ :-**

មន្ទីរពិសោធន៍គ្រឿងញៀន មានភារកិច្ចដូចតទៅ :

១. ធ្វើវិភាគ ស្រាវជ្រាវ តាមបែបវិទ្យាសាស្ត្រ លើលក្ខណៈគីមី និងលក្ខណៈរូបនៃសារធាតុគ្រឿងញៀន និង គីមីផ្សំ គ្រឿងញៀនដែលបានកំណត់ក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា នៅក្នុងរុក្ខជាតិ សារធាតុគីមី វត្ថុធាតុដែលមាននៅក្នុងសរីរាង្គមនុស្ស ចំណីអាហារ ភេសជ្ជៈ និង ឱសថបុរាណ/សម័យ ។

២. ធ្វើការវិភាគរកគុណភាព បរិមាណសារធាតុញៀន និងគីមីផ្សំគ្រឿងញៀនដែលក្រសួង-ស្ថាប័នមានសមត្ថកិច្ចប្រគល់ជូន និងផ្តល់ជូននូវលទ្ធផលនៃការវិភាគទាំងនេះវិញ ។

៣. ធ្វើការផលិតសារធាតុប្រតិករសំរាប់ធ្វើតេស្តពណ៌ជំហានដំបូងលើសារធាតុញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន ។

៤. ធ្វើការសិក្សាស្រាវជ្រាវរកសារធាតុញៀន ឬ សារធាតុគីមីផ្សំគ្រឿងញៀនថ្មី ឬ សារធាតុពុលផ្សេងទៀត ដែលនាំឱ្យប៉ះពាល់ដល់សុខភាព ដើម្បីដាក់ចូលទៅក្នុងតារាងត្រួតពិនិត្យសារធាតុគ្រឿងញៀននៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសហការជាមួយក្រសួងសុខាភិបាល និងមន្ទីរពិសោធន៍ ផ្សេងៗទៀតដែលពាក់ព័ន្ធ ។

៥. ធ្វើការរក្សាទុក វិភាគ និង ប្រៀបធៀបទិន្នន័យ ស្តីពីលក្ខណៈរូប លក្ខណៈគីមី ដើម្បីរកពត៌មានចាំបាច់ដែលពាក់ព័ន្ធសំរាប់បំរើការងារស៊ើបអង្កេត ។

៦. លើកសំណើជូនអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្តីពីការផលិត និងការធ្វើជំនួញឱសថសម័យ ឱសថបុរាណ ភេសជ្ជៈ គ្រឿងស្រវឹង គ្រឿងបរិភោគនៅក្នុងប្រទេស និងថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដែលមន្ទីរពិសោធន៍គ្រឿងញៀនស្រាវជ្រាវរកឃើញថា មានសារធាតុគ្រឿងញៀនលើសកំរិតសុវត្ថភាព ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពសង្គម ដើម្បីធ្វើការហាមឃាត់ ។

មន្ទីរពិសោធន៍គ្រឿងញៀនត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធានមន្ទីរពិសោធន៍មួយរូប និងមានអនុប្រធានជាជំនួយការ ។

## ជំពូក ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៤ :-**

រាល់អនុក្រឹត្យ និងសេចក្តីសំរេចពីមុនដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៥ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពដែលពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ១៦ :-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីទៅជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ស ខេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៥
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន
# នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

